ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខៈ ៧០៩ ...... សហវ.ប្រក.

ប្រកាស
ស្តីពីការដកហូតអាជ្ញាប័ណ្ណ
អាជីវកម្មភ្នាល់កីឡារបស់ក្រុមហ៊ុន Cambo Six Co., Ltd.

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញលិខិតលេខ ១៧៩៥ សជណ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអាជ្ញាប័ណ្ណលេខ ០០១ សហវ.ឧហ ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៧ ផ្តល់ជូនលោកនាយកក្រុមហ៊ុន Cambo Six Co., Ltd.
- បានឃើញសេចក្តីណែនាំលេខ ០១ សណន ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល
- បានឃើញសេចក្តីជូនដំណឹងលេខ ០០១ សហវ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ប្រការ ១ : ដកហូតអាជ្ញាប័ណ្ណលេខ ០០១ សហវ.ឧហ ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៧ របស់ក្រុមហ៊ុន Cambo Six Co., Ltd. តាមស្មារតីនៃសេចក្តីជូនដំណឹងលេខ ០០១ សហវ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ ២ : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ លោកប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីក្រុមហ៊ុន ត្រូវទទួលអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៣ : ប្រកាសនេះ មានសុពលភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ✓
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងពាណិជ្ជកម្ម
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- គ្រប់សាលាខេត្ត-ក្រុង និងស្ថាប័នពាក់ព័ន្ធ
  " ដើម្បីជូនជ្រាប "
- ឯកសារ-កាលប្បវត្តិ